ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំយុវជន និង កីឡា

លេខ : ៤០៦ អយក.ប្រក

# ប្រកាស

## ស្តីពីការបើកសាលាបឋមសិក្សា និង មត្តេយ្យចំណេះទូទៅ អង្គរ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតលោក ទាន់ សុផល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០១ ដោយមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត កំពង់ស្ពឺ លេខ ៤៤២ អយក.កម ចុះថ្ងៃទី ២៦ ខែ ០២ ឆ្នាំ ២០០២ ។
- តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១** :- អនុញ្ញាតអោយលោក ទាន់ សុផល បើកសាលាឯកជនបឋម និង មត្តេយ្យចំនេះទូទៅ អង្គរ ដែលមានទីតាំងស្ថិតនៅភូមិ ត្រពាំងស្លើក ឃុំ រការធំ ស្រុក ឧដុង្គ ខេត្ត កំពង់ស្ពឺ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- ចំពោះមុខសាលានេះ និង បណ្តុះបណ្តាលចំនេះទូទៅតាមបែបអន្តរជាតិ ដែលចែកចេញជាថ្នាក់សំរាប់សិក្សារយៈពេល ១ ឆ្នាំ ។

| | | |
|---|---|---|
| -ថ្នាក់កំរិតទាប Lower Step | - ថ្នាក់ទី ១ Grade One | - ថ្នាក់ទី ៤ Grade Four |
| -ថ្នាក់កំរិតមធ្យម Medium Step | - ថ្នាក់ទី ២ Grade Two | - ថ្នាក់ទី ៥ Grade Five |
| -ថ្នាក់កំរិតខ្ពស់ High Step | - ថ្នាក់ទី ៣ Grade Three | - ថ្នាក់ទី ៦ Grade Six |

ទៅអនាគតសាលានេះ និង អាចពង្រីកបើកបន្ថែមទៅតាមលទ្ធភាពរបស់ខ្លួន ។

**ប្រការ៣** :- ការទទួលសិស្សអោយចូលរៀន : សិស្សទាំងពីរភេទត្រូវមានអាយុ ចាប់ពី ៣ ឆ្នាំ ឡើងទៅពេញ :

**ប្រការ៤** :-លោក ទាន់ សុផល មានភារកិច្ច :

- ជ្រើសរើសសិស្សអោយចូលរៀន គ្រូបង្រៀន ដំណើរការបង្រៀន ឯកសារសិក្សា ការប្រលង និង ការប្រគល់វិញ្ញាបនប័ត្របញ្ចប់ការសិក្សា ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំរបស់រដ្ឋ ។
- ធានាអោយបាននូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និង កីឡា

**ប្រការ៥** :- ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិធ្វើអធិការកិច្ចត្រួតពិនិត្យ ហើយមានសិទ្ធិបិទ ប្រសិនបើសាលានេះ អនុវត្តខុសពីច្បាប់រដ្ឋ ។

**ប្រការ៦** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡាមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ស្ពឺ ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ឧដុង្គ នាយកសាលាបឋម និង មត្តេយ្យចំនេះទូទៅ អង្គរ និង លោក ទាន់ សុផល មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០០២

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត កំពង់ស្ពឺ

"ដើម្បីជូនជ្រាបជាពត៌មាន"

- ដូចប្រការ ៦
- កាលប្បវត្តិ - ឯកសារ ទា -ប.ម